# ព្រះរាជក្រឹត្យ
# ស្តីពី

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិសម្រាប់ជានិមិត្តរូប
## នៃព្រះរាជាណាចក្រកម្ពុជា



ខែ មីនា ឆ្នាំ ២០០៥

បោះពុម្ពផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ព្រះរាជក្រឹត្យ
# ស្តីពី

ម.ព.ឯ.ក AIDOC
Code: 018-029
Date:
Donated by:

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិសម្រាប់ជានិមិត្តរូប
## នៃព្រះរាជាណាចក្រកម្ពុជា

ខែ មីនា ឆ្នាំ ២០០៥

នស/រកត/០៣០៥/១៤៩

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូប

## នៃព្រះរាជាណាចក្រកម្ពុជា

☆☆☆☆☆

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ព្រះរាជក្រឹត្យ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឈ្មោះសត្វ និង រុក្ខជាតិ ដែលមានអត្ថិភាព និង សារប្រយោជន៍ពិសេស សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញនូវមរតកធម្មជាតិដ៏មានតម្លៃ និង លើកតម្កើងនូវមោទនភាពជាតិ ។

**មាត្រា ២.-**

សត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

| | | |
|---|---|---|
| ១- ប្រភេទសត្វចតុប្បាទ | : | សត្វគោព្រៃ |
| ២- ប្រភេទបក្សី | : | សត្វត្រយ៉ង |
| ៣- ប្រភេទឧរង្គសត្វ | : | អណ្ដើកសរសៃ ( អណ្ដើកហ្លួង) |
| ៤- ប្រភេទមច្ឆា | : | ត្រីគល់រាំង |
| ៥- ប្រភេទរុក្ខជាតិ | : | ដើមត្នោត |
| ៦- ប្រភេទផ្កា | : | ផ្ការំដួល |
| ៧- ប្រភេទផ្លែឈើ | : | ផ្លែចេកពងមាន់ |

រូបភាព និង លក្ខណៈវិនិច្ឆ័យនៃសត្វ និង រុក្ខជាតិនីមួយៗ ដូចចែងខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ ទី៥ និង ទី៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

សត្វ និង រុក្ខជាតិ ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវមានវិធានការថែរក្សាការពារ អភិរក្សឱ្យមាននិរន្តរភាព និង ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

**មាត្រា ៤.-**

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង. រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

៣កល.០៥០៣.១៥៥

លេខ : ១២៤.ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# <u>ឧបសម្ព័ន្ធ ទី១</u>

## នៃព្រះរាជក្រឹត្យលេខ នស.រកត / ០៣០៥ / ១៤៩ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥
## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ១- គោព្រៃ (*Bos sauveli*) ជាសត្វចតុប្បាទនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះ **គោព្រៃ** ជាន័យដើម និង ន័យត្រង់នៃភាសាជាតិខ្មែរតែម្តង ហើយត្រូវបានសត្វវិទូអន្តរជាតិទទួលស្គាល់ និង ដាក់នាមដូច១គ្នា ទោះជាភាសាអង់គ្លេស អេស្ប៉ាញ និង បារាំង គឺប្រើពាក្យតែមួយ "**Kouprey**"។ វាមានឈ្មោះវិទ្យាសាស្ត្រ " *Bos sauveli* " មានប្រវែងដងខ្លួនពី ២,១-២,៣ ម៉ែត្រ មានកម្ពស់ពី ១,៧-១,៩ ម៉ែត្រ និង ទម្ងន់ពី ៧០០-៩០០ គីឡូក្រាម។ គោព្រៃមានរូបរាងស្រដៀងនឹងទន្សោង មានប្ញូវែងធ្លាក់ចុះដល់ជង្គង់ និង ហៀរស្ទើរតែដល់ដីចំពោះគោឈ្មោល ។ ស្នែងគោព្រៃឈ្មោល និង ញី មានលក្ខណៈប្លែកគ្នា ដោយស្នែងឈ្មោលធំជាង ដុះចេញកោងទៅមុខ និង ងើបឡើងលើ ព្រមទាំងមានព្រុយចុងស្នែង។ ស្នែងញីដុះមកខាងមុខរាងងើបបន្តិច ហើយគួចរមួលឡើងលើ។ ចាប់ពីជើងក្រោមជង្គង់ចុះមក មានពណ៌ស ឬ ប្រផេះ និង ប្រផេះចាស់នៅពេលមានអាយុច្រើន ។ កាលពីសម័យមុនសង្គ្រាម គោព្រៃត្រូវហាមបរបាញ់តាមរយៈប្រកាសលេខ ១៩១ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៦០។ ក្រោយរបប **ប៉ុល ពត** គោព្រៃក៏ត្រូវហាមបរបាញ់ម្តងទៀតតាមរយៈប្រកាសលេខ ៣៥៩ កសក.ប្រក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ គោព្រៃត្រូវហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយបានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES និង អនុសញ្ញា Convention on Migratory Species ។ ពិភពលោកបានចាត់ទុកគោព្រៃជាប្រភេទសត្វ **ជិតផុតពូជបំផុត** (Critical Endangered) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN។ ក្នុងទសវត្សឆ្នាំ ៦០ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ និង ប្រកាសថាៈ គោព្រៃជានិមិត្តរូបនៃមរតកធម្មជាតិកម្ពុជា។ គោព្រៃក៏ត្រូវចារឹកទុកនៅក្នុងបទចំរៀងប្រជាប្រិយរបស់ខ្មែរតាំងពីយូរយារណាស់មកហើយ ជាពិសេសបទចំរៀងដែលមានលក្ខណៈរៀបរាប់អំពីធម្មជាតិ ប្រដូចភាពសុខសាន្តនៃការរស់នៅរវាងមនុស្ស សត្វ និង ធម្មជាតិ គឺតែមួយ ។ គោព្រៃជាថនិកសត្វស្លូតរស់នៅជាហ្វូង១ អាចឃើញមាននៅលាយជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើស។ ជាសត្វវៀងវៃ រហ័សរហួន ឆាប់ភ្ញាក់ផ្អើលជាងប្រភេទសត្វក្នុងត្រកូលគោសាទិសដូចគ្នា ពូកែស្រង់ក្លិន និង គេចវេសចេញពីមនុស្ស ។ មានកម្លាំងខ្លាំង ពូកែធន់នឹងកំដៅថ្ងៃ អត់ធន់នឹងចំណីអាហារដែលមានគុណភាពទាប និង ធន់នឹងជំងឺគោឆ្កួត។
~~~~~